ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៧៩១៤ ព.ណ.ន.ជ

ថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់ឲ្យបានជ្រាបថា៖ ព្រះរាជាណាចក្រកម្ពុជា បានសម្រេចចូលរួមអនុវត្តគម្រោងប្រើប្រាស់វិក្កយបត្រសម្រាប់ធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន (ASEAN-Wide Self-Certification-AWSC) ចាប់ពីថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០២០ តទៅ ក្នុងគោលដៅសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងតំបន់។

ផលិតករ ឬអ្នកនាំចេញ ដែលមានបំណងចូលរួមអនុវត្តនូវការប្រើប្រាស់វិក្កយបត្រសម្រាប់ធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន និងដើម្បីឱ្យការអនុវត្តមានប្រសិទ្ធភាព សង្គតិភាព និងអនុលោមភាពជាមួយនឹងការអនុវត្តនីតិវិធីប្រតិបត្តិនៃការបញ្ជាក់ដើមកំណើតទំនិញដែលត្រូវបានគាំទ្រដល់ការអនុវត្តនូវការប្រើប្រាស់វិក្កយបត្រសម្រាប់ធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាននេះ សូមមកទាក់ទងសាកសួរព័ត៌មានរៀងរាល់ម៉ោងធ្វើការ តាមកាលបរិច្ឆេទ និងទីកន្លែងដូចខាងក្រោម៖

| | |
|---|---|
| -កាលបរិច្ឆេទ: | ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ |
| -ទីកន្លែង: | នាយកដ្ឋាននាំចេញ នាំចូល នៃក្រសួងពាណិជ្ជកម្ម (អគារ គ) ជាន់ទី១ និងទី២ |
| -ទូរស័ព្ទទំនាក់ទំនង: | ០១២ ៨៣៣ ៣៩៧ ឬ ០១៦ ៦១៣ ៨៨៨ ឬ ០១១ ៧៥៧ ១៦៥ |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ជាផលិតករ ឬអ្នកនាំចេញទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469